# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៦ ស.អ.ន

## សេចក្តីអំពាវនាវ
## របស់រាជរដ្ឋាភិបាលកម្ពុជា

ថ្ងៃអាទិត្យ ទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០២ ជាទិវាប្រវត្តិសាស្ត្រ ដែលប្រជាពលរដ្ឋកម្ពុជាទូទាំងប្រទេស ប្រារព្ធការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ជាលើកដំបូង ដើម្បីអនុវត្តលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន និងអនុវត្តនយោបាយវិមជ្ឈការ ដូចបានកំណត់ក្នុងច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ។

អនុលោមតាមសេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា លេខ ០១ ស.អ.ន ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០២ និងក្នុងគោលបំណងពង្រឹងស្ថិរភាព សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយ ជៀសវាងការប្រើអំពើហិង្សាផ្សេងៗជាយថាហេតុនោះ រាជរដ្ឋាភិបាល សូមអំពាវនាវដល់ប្រជាពលរដ្ឋជាជនរួមជាតិទាំងអស់ សូមអញ្ជើញទៅធ្វើការបោះឆ្នោត ដើម្បីជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ របស់ខ្លួនអោយបានគ្រប់ៗគ្នា និងសូមអំពាវនាវដល់ជនរួមជាតិទាំងអស់ សូមកុំពិសារស្រា ឬ ភេសជ្ជៈស្រវឹង នៅក្នុងថ្ងៃបោះឆ្នោត នាថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០២ ខាងមុខនេះ ។

រាជរដ្ឋាភិបាលសង្ឃឹមថា ជនរួមជាតិទាំងអស់នឹងចូលរួមចំណែកអនុវត្តតាមសេចក្តីអំពាវនាវនេះ ដោយក្តីសោមនស្សរីករាយ និងស្មារតីទទួលខុសត្រូវខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**